**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៣៥ អនក្រ.បក

# អនុក្រឹត្យ

## ស្ដីពី

## ការបង្កើតគណៈកម្មការត្រួតពិនិត្យ
## យានយន្តដឹកជញ្ជូនលើសទំងន់កំរិតកំណត់អតិបរមា

***

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦.០៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ ១៤ អនក្រ.បក ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ១៩៩៨ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសាធារណៈការ និងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ ៨៣ អនក្រ.បក ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ១៩៩៩ ស្ដីពីការកំណត់ទំងន់អតិបរមា នៃយានយន្តដឹកជញ្ជូនផ្លូវគោក ដែលបើកបរលើបណ្ដាញផ្លូវជាតិ នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមការចាំបាច់នៃការងារ

**សំរេច**

**មាត្រា ១.-**

បង្កើតគណៈកម្មការត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទំងន់កំរិតកំណត់អតិបរមាគ្រប់ប្រភេទ ដែលបើកបរលើបណ្ដាញផ្លូវជាតិ នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីរួមចំណែកក្នុងការថែរក្សាគុណភាពផ្លូវជាតិ និងស្ពានទាំងឡាយឱ្យស្ថិតស្ថេរយូរអង្វែង ។

**មាត្រា ២.-**

គណៈកម្មការត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទំងន់កំរិតកំណត់អតិបរមា មានសមាសភាពដូចតទៅ :

| | |
|---|---|
| ១- រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន | ប្រធាន |
| ២- រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ទទួលបន្ទុកការងាររដ្ឋបាល មួយរូប | អនុប្រធាន |
| ៣- រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៤- អគ្គស្នងការនគរបាលជាតិ | សមាជិក |
| ៥- មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស | សមាជិក |
| ៦- អភិបាលរងខេត្ត ក្រុងមួយរូប | សមាជិក |
| ៧- ប្រធានគណៈកម្មការសំរបសំរួលអចិន្ត្រៃយ៍ | សមាជិកអចិន្ត្រៃយ៍ |

ប្រធានគណៈកម្មការត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទំងន់កំរិតកំណត់អតិបរមា អាចអញ្ជើញតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធដទៃទៀត និងអភិបាលខេត្ត ក្រុង ចូលរួមប្រជុំតាមការចាំបាច់ ។ គណៈកម្មការនេះមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងសាធារណការ និងដឹកជញ្ជូន ។

**មាត្រា ៣.-**

គណៈកម្មការត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទំងន់កំរិតកំណត់អតិបរមា មានភារកិច្ច :

- រៀបចំ និងដាក់ចេញនូវវិធានការឱ្យអនុវត្តការត្រួតពិនិត្យ និងការទប់ស្កាត់រាល់ការដឹកជញ្ជូនលើសទំងន់កំរិតកំណត់អតិបរមាលើផ្លូវជាតិ ក្នុងព្រះរាជាណាចក្រកម្ពុជា
- សំរបសំរួល តាមដាន ត្រួតពិនិត្យការអនុវត្តការងាររបស់គណៈកម្មការសំរបសំរួលអចិន្ត្រៃយ៍
- រាយការណ៍ជូនរាជរដ្ឋាភិបាល អំពីសកម្មភាពត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទំងន់កំរិតកំណត់អតិបរមា
- អនុវត្តភារកិច្ចផ្សេងៗ តាមការប្រគល់ជូនរបស់រាជរដ្ឋាភិបាល ។

**មាត្រា ៤.-**

គណៈកម្មការត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទំងន់កំរិតកំណត់អតិបរមា មានគណៈកម្មការសំរបសំរួលអចិន្ត្រៃយ៍ ជាសេនាធិការទទួលបន្ទុកការងារសំរបសំរួល តាមដានជាប្រចាំការអនុវត្តន៍ការងារបង្ក្រាបរាល់ការដឹកជញ្ជូនលើសទំងន់កំរិតកំណត់អតិបរមាលើផ្លូវជាតិក្នុងព្រះរាជាណាចក្រកម្ពុជា ។

គណៈកម្មការសំរបសំរួលអចិន្ត្រៃយ៍មានសមាសភាពដូចតទៅ :

| | |
|---|---|
| ១- តំណាងរដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន | ប្រធាន |
| ២- តំណាងអគ្គនាយកដ្ឋានសាធារណការ នៃក្រសួងសាធារណការ និងដឹកជញ្ជូន | អនុប្រធាន |
| ៣- តំណាងក្រសួងមហាផ្ទៃ | អនុប្រធាន |
| ៤- តំណាងកងរាជអាវុធហត្ថលើផ្ទៃប្រទេស | អនុប្រធាន |
| ៥- តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |

៦- តំណាងអគ្គាធិការដ្ឋាននៃក្រសួង ស.ដ.ក សមាជិក

៧- តំណាងអគ្គនាយកដ្ឋានដឹកជញ្ជូននៃក្រសួង ស.ដ.ក សមាជិក

គណៈកម្មការសំរបសំរួលអចិន្ត្រៃយ៍ ត្រូវតែងតាំងដោយសេចក្តីសំរេចរបស់ប្រធានគណៈកម្មការត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទំងន់កំរិតកំណត់អតិបរមា ។

**មាត្រា ៥.-**

គណៈកម្មការសំរបសំរួលអចិន្ត្រៃយ៍ មានភារកិច្ច :

- បង្កើត និងរៀបចំសមាសភាពក្រុមត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទំងន់កំរិតកំណត់អតិបរមា
- សំរបសំរួល ជំរុញត្រួតពិនិត្យសកម្មភាពរបស់ក្រុមត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទំងន់កំរិតកំណត់អតិបរមា
- រៀបចំកម្មវិធីត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទំងន់កំរិតកំណត់អតិបរមា
- រៀបចំធ្វើសេចក្តីកំណត់តួនាទី និងភារកិច្ចរបស់ក្រុមត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទំងន់កំរិតកំណត់អតិបរមា
- រៀបចំ និងចាត់ចែងធ្វើតារាងបែងចែកដាក់ និងផ្លាស់ប្តូរទីតាំងត្រួតពិនិត្យ សំរាប់ក្រុមត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទំងន់កំរិតកំណត់អតិបរមា
- រៀបចំបេសកកម្ម ព្រមទាំងតាមដានរាល់សកម្មភាពរបស់ក្រុមត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទំងន់កំរិតកំណត់អតិបរមា
- ទំនាក់ទំនង និងសហការយ៉ាងជិតស្និទ្ធ ជាមួយអាជ្ញាធរដែនដី ខេត្ត ក្រុង
- អនុវត្តការផាកពិន័យតាមកំហុសជាក់ស្តែង ដោយយោងទៅតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន
- អនុវត្តភារកិច្ចផ្សេងៗទៀត ដែលគណៈកម្មការត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទំងន់កំរិតកំណត់អតិបរមា ប្រគល់ជូន ។

គណៈកម្មការសំរបសំរួលអចិន្ត្រៃយ៍ អាចប្រើប្រាស់មន្ត្រីជំនាញ តាមសមត្ថកិច្ចរៀងៗខ្លួនតាមពេលវេលា និងទំហំការងារចាំបាច់ ។

**មាត្រា ៦.-**

គណៈកម្មការសំរបសំរួលអចិន្ត្រៃយ៍មានតួនាទីគ្រប់គ្រងប្រាក់ចំណូលដែលបានមកពីការផាកពិន័យ ដើម្បីបង់ចូលថវិកាជាតិ ។

**មាត្រា ៧.-**

គណៈកម្មការសំរបសំរួលអចិន្ត្រៃយ៍ ត្រូវកំណត់បទបញ្ជាផ្ទៃក្នុង បែងចែកភារកិច្ច និងរៀបចំកម្មវិធីចុះបេសកកម្ម ។ ក្រោយពេលចុះបេសកកម្ម ត្រូវធ្វើរបាយការណ៍អំពីលទ្ធផល និងវិធានការដោះស្រាយរបស់ក្រុមត្រួតពិនិត្យ ជូនគណៈកម្មការត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទំងន់កំរិតកំណត់អតិបរមា ដើម្បីពិនិត្យ និងលើកគោលការណ៍ វិធានការ សំរាប់ណែនាំអនុវត្តបន្ត ។

**មាត្រា ៨.-**

ក្រុមត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទំងន់កំរិតកំណត់អតិបរមានីមួយៗ មានសមាសភាពដូចតទៅ :

១- តំណាងមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្ត ក្រុង ប្រធាន

២- តំណាងអាជ្ញាធរដែនដីខេត្ត ក្រុង អនុប្រធាន

៣- តំណាងកងរាជអាវុធហត្ថប្រចាំខេត្ត ក្រុង សមាជិក

៤- តំណាងស្នងការដ្ឋាននគរបាលខេត្ត ក្រុង សមាជិក

៥- តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក

៦- មន្ត្រីជំនាញដែលមានចំនួនទៅតាមការចាំបាច់ជាក់ស្តែងរបស់ក្រុមត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទំងន់កំរិតកំណត់អតិបរមា មានជាអាទិ៍ : ជំនាញជញ្ជីង នគរបាល កងរាជអាវុធហត្ថ សមាជិក

**មាត្រា ៩.-**

ក្រុមត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទំងន់កំរិតកំណត់អតិបរមានីមួយៗ មានភារកិច្ច :

- ត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទំងន់កំរិតកំណត់អតិបរមា
- ផាកពិន័យតាមការណែនាំរបស់គណៈកម្មការត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទំងន់កំរិតកំណត់អតិបរមា
- អនុវត្តតាមបទបញ្ជា ហើយរាយការណ៍ជូនគណៈកម្មការសំរបសំរួលអចិន្ត្រៃយ៍ជាប្រចាំ
- អនុវត្តការផាកពិន័យតាមកំហុសជាក់ស្តែង ដោយយោងទៅតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន
- អនុវត្តភារកិច្ចផ្សេងៗទៀត ដែលគណៈកម្មការសំរបសំរួលអចិន្ត្រៃយ៍ប្រគល់ជូន ។

**មាត្រា ១០.-**

ក្រោយពេលដែលអនុក្រឹត្យនេះចូលជាធរមាន ដើម្បីបន្តនិរន្តរភាពនៃសកម្មភាពត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទំងន់កំរិតកំណត់អតិបរមា គណៈកម្មការចំរុះត្រួតពិនិត្យលើមធ្យោបាយដឹកជញ្ជូនគ្រប់ប្រភេទ និងអនុគណៈកម្មការអចិន្ត្រៃយ៍ត្រួតពិនិត្យលើមធ្យោបាយដឹកជញ្ជូនគ្រប់ប្រភេទ ដែលបង្កើតដោយប្រកាសលេខ ០៤៨ ប្រក.ស.ក.បធ ចុះថ្ងៃទី ២៩ ខែមករា ឆ្នាំ ២០០១ របស់ក្រសួងសាធារណការ និងដឹកជញ្ជូន ត្រូវបន្តសកម្មភាពត្រួតពិនិត្យរបស់ខ្លួន នៅលើបណ្តាញផ្លូវជាតិទាំងអស់ រួមទាំងផ្លូវជាតិលេខ៥ និងផ្លូវពីប៉ោយប៉ែត ទៅសៀមរាបផងដែរ ដោយត្រូវក្លាយជាគណៈកម្មការសំរបសំរួលអចិន្ត្រៃយ៍ និងក្រុមត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទំងន់កំរិតកំណត់អតិបរមា ។

**មាត្រា ១១.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

.. ៤/.

**មាត្រា ១២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ [illegible] ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

បានឃើញ និងជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី សូមចុះហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងសាធារណការ**

**និងដឹកជញ្ជូន**

**ឃឹម សារឹងលីម**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១២
- រាជកិច្ច √
- កាលប្បវត្តិ ឯកសារ